# ប័ណ្ណព័ត៌មាន៖ អំពើហិង្សាក្នុងគ្រួសារ

អំពើហិង្សាក្នុងគ្រួសារ គឺជាអាកប្បកិរិយាណាមួយដែលរំលោភបំពានលើរាងកាយ ផ្លូវភេទ ផ្លូវអារម្មណ៍ឬផ្លូវចិត្ត ការគំរាមកំហែង ឬតាមវិធីណាមួយទៀតដែលគ្រប់គ្រង ឬគ្រួតត្រាសមាជិកគ្រួសារ ឬធ្វើឲ្យពួកគេភ័យខ្លាច។ អំពើហិង្សាត្រូវគេប្រើដើម្បីទទួលបាននូវអំណាច និងការគ្រប់គ្រងលើសមាជិកណាមួយនៃក្រុមគ្រួសារ។

អំពើហិង្សាមិនត្រឹមតែទាក់ទងនឹងរាងកាយប៉ុណ្ណោះទេ។ អំពើហិង្សាក្នុងគ្រួសារអាចទាក់ទងនឹងផ្លូវភេទ អារម្មណ៍ ផ្លូវចិត្ត សង្គម សេដ្ឋកិច្ច ពាក្យសំដី និងជំនឿដែរ។

## ប្រភេទនានានៃអំពើហិង្សាក្នុងគ្រួសារ

### ខាងសង្គម
ការញែកផ្តាច់មនុស្សម្នាក់ចេញពីក្រុមគ្រួសារ មិត្តភក្តិ និងរង្វង់សង្គមមនុស្សឯទៀត

### ខាងពាក្យសំដី
ការចំអកឡកឡឺយ និងការប្រមាថ ដោយពាក្យសំដី ដែលសើចចំអក ឬមើលងាយមនុស្សណាម្នាក់

### ខាងផ្លូវភេទ
សកម្មភាព ឬការយាយីផ្លូវភេទទាំងបង្ខំ និងមិនចង់បាន

### ខាងផ្លូវអារម្មណ៍
អាកប្បកិរិយា និងសកម្មភាព ដែលបណ្តាលឲ្យឈឺចាប់ខាងផ្លូវចិត្ត

### ខាងសេដ្ឋកិច្ច
អាកប្បកិរិយា និងសកម្មភាពដែល គ្រប់គ្រងលុយកាក់របស់ជនណាម្នាក់ ហើយមិនអនុញ្ញាតឲ្យជននោះ ចាត់ចែងលុយកាក់ដោយខ្លួនឯងឡើយ

### ខាងជំនឿ
ការប្រើជំនឿសាសនា ឬជំនឿផ្ទាល់ខ្លួន ដើម្បីបង្ហាញហេតុផលត្រឹមត្រូវនៃ អំពើហិង្សា ឬបដិសេធចំពោះបុគ្គល ណាម្នាក់មិនឲ្យមានជំនឿសាសនា ជាក់លាក់ណាមួយ

### ខាងរាងកាយ
ការប្រើកម្លាំងរាងកាយ ដើម្បីបង្កការឈឺចាប់ និងរបួស

### ខាងផ្លូវចិត្ត
អាកប្បកិរិយា និងសកម្មភាពដែលធ្វើឲ្យ មនុស្សណាម្នាក់មានអារម្មណ៍គ្រោះថ្នាក់ គ្មានអំណាច និងជាប់អន្ទាក់រើខ្លួនពុំរួច

**ប្រភព៖** *National Council to Reduce Violence against Women and their Children. (2009)*. Background paper to Time for Action: The National Council's Plan for Australia to Reduce Violence against Women and their Children, 2009-2021. *National Council to Reduce Violence against Women and their Children. Canberra.*

---

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

City of Casey · Cardinia · Greater Dandenong City of Opportunity · MonashHealth · Victoria State Government

# ប័ណ្ណព័ត៌មាន៖ អំពើហិង្សាលើស្ត្រី

អំពើហិង្សាលើស្ត្រី គឺជាប្រភេទនៃអំពើហិង្សាណាមួយដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ឬបង្កការឈឺចាប់ដល់ស្ត្រី។

ជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារភាគច្រើន គឺស្ត្រី ហើយជនដែលប្រព្រឹត្តបទល្មើសភាគច្រើន គឺបុរស។

"ជនដែលប្រព្រឹត្តបទល្មើសជាង

**9 នាក់ ក្នុងចំណោមជនល្មើស 10 នាក់**

នៃអំពើហិង្សាលើស្ត្រី គឺបុរស។





ស្ត្រីទំនងជាខ្លាំងក្នុងការជួបប្រទះនឹងអំពើហិង្សានេះ ពីបុរសដែលជាអតីតដៃគូសម្ព័ន្ធភាព

**ឬដៃគូសម្ព័ន្ធភាពបច្ចុប្បន្ន**




28 ភាគរយនៃស្ត្រីបានឆ្លងកាត់អំពើហិង្សាពីបុរសដែលជាអតីតដៃគូ ឬដៃគូសម្ព័ន្ធភាពបច្ចុប្បន្ន បុរសសង្សារ ឬអ្នកណាត់ជួប

**ប្រភព៖**

Australian Bureau of Statistics. (2012). *Personal Safety Survey*. Canberra: Australian Bureau of Statistics.

Diemer, K. (2012). *Measuring family violence in Victoria: Victorian family violence database (Volume 5).* Melbourne, Victoria: Department of Justice.

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ គំនិតមិនត្រឹមត្រូវទូទៅអំពី អំពើហិង្សាលើស្ត្រី

គំនិតមិនត្រឹមត្រូវទី 1

## បុរសគួរធ្វើការសម្រេចចិត្ត និងធ្វើការគ្រប់គ្រងក្នុងទំនាក់ទំនងសម្ព័ន្ធភាព។

**ការពិត៖ អំពើហិង្សាច្រើនកើតឡើងនៅក្នុងគ្រួសារ និងទំនាក់ទំនងសម្ព័ន្ធភាព ដែលក្នុងនោះបុរសគ្រប់គ្រងលើការធ្វើសេចក្តីសម្រេចចិត្ត ហើយកើតមានតិចតួចក្នុងទំនាក់ទំនងសម្ព័ន្ធភាពទាំងនោះ ដែលក្នុងនោះស្ត្រីមានភាពឯករាជ្យម្ចាស់ការច្រើន។**

ការមានជំនឿថាបុរស និងស្ត្រីមានតួនាទី ឬចរិតលក្ខណៈផ្សេងៗគ្នា (ទោះជានៅក្នុងទំនាក់ទំនងសម្ព័ន្ធភាព ឬសង្គមជាទូទៅក្តី) ត្រូវបានគេស្គាល់ថាជាផ្នត់គំនិតបំផ្លើសខាងហ្ស៊ីនឌ័រ(gender)។ ការសិក្សាអន្តរជាតិនានា បានបង្ហាញម្តងហើយម្តងទៀតថាជំនឿក្នុងផ្នត់គំនិតបំផ្លើសបែបនេះ គឺជាផ្នែកមួយនៃការស្មានទុកមុនដ៏ខ្លាំងក្លាបំផុតនៃអំពើហិង្សា។ ពោលគឺ បុគ្គលដែលមានជំនឿបែបនេះទំនងជាប្រព្រឹត្តអំពើហិង្សាលើស្ត្រី ហើយបណ្តាប្រទេសទាំងឡាយដែលច្រើនទទួលយកផ្នត់គំនិតបំផ្លើសខាងភេទ គឺមានអំពើហិង្សាលើស្ត្រីក្នុងអត្រាខ្ពស់។

យើងដឹងថា នៅក្នុងបណ្តាសង្គមដែលបុរស និងស្ត្រីមានភាពស្មើគ្នាក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ពួកគេ ហើយដែលពួកគេមិនត្រូវបានរំពឹងថានឹងមានតួនាទីផ្សេងៗគ្នាដោយផ្អែកលើភេទរបស់ពួកគេនោះអំពើហិង្សាមិនសូវជាកើតមានឡើងឡើយ។ សមភាពកាន់តែច្រើន និងតួនាទីហ្ស៊ីនឌ័រដែលមានភាពបត់បែនកាន់តែច្រើន ផ្តល់ដល់មនុស្សគ្រប់គ្នានូវឱកាសកាន់តែច្រើន ដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនឲ្យបានពេញលេញ។

គំនិតមិនត្រឹមត្រូវទី 2

## អំពើហិង្សាក្នុងគ្រួសារអាចទទួលយកបាន ប្រសិនបើនរណាម្នាក់ខឹងខ្លាំងរហូតដល់បាត់បង់ការគ្រប់គ្រងខ្លួនឯង។

**ការពិត៖ អំពើហិង្សាលើស្ត្រី គឺជាទង្វើអ្វីមួយច្រើនជាងគ្រាន់តែជាការទប់កំហឹងមិនបានរបស់លោកអ្នក។**

គ្មានការដោះសារណាមួយសម្រាប់អាកប្បកិរិយាអំពើហិង្សានោះទេ។ គឺគ្មានទាល់តែសោះ។ អំពើហិង្សាត្រូវបានបង្កឡើងដោយឥរិយាបទរបស់បុគ្គលម្នាក់ទៅលើស្ត្រី និងឥរិយាបទសង្គមដែលនិយាយថា អំពើហិង្សារបស់បុរសលើស្ត្រីគឺមិនអីទេ។

គំនិតមិនត្រឹមត្រូវទី 3

## ស្ត្រីអាចចាកចេញពីទំនាក់ទំនងសម្ព័ន្ធភាពដែលមានអំពើហិង្សា ប្រសិនបើគេចង់។

**ការពិត៖ ស្ត្រីមានការប្រឈមមុខនឹងអំពើហិង្សាធ្ងន់ធ្ងរ ដោយមានរួមទាំងការធ្វើឃាត ពេលព្យាយាមចាកចេញ ឬបន្ទាប់ពីការចាកចេញពីទំនាក់ទំនងសម្ព័ន្ធភាពដែលមានអំពើហិង្សា។ ស្ត្រីយល់ឃើញថាវាមានការលំបាកខ្លាំងណាស់ក្នុងការចាកចេញពីទំនាក់ទំនងសម្ព័ន្ធភាពដែលមានអំពើហិង្សា ដោយសារមានការភ័យខ្លាចចំពោះសុវត្ថិភាព និងសុវត្ថិភាពរបស់កូន។**

យើងមិនត្រូវទម្លាក់កំហុសលើស្ត្រីចំពោះអំពើហិង្សានេះឡើយ ប្រសិនបើស្ត្រីមិនចាកចេញ។

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

City of Casey | Cardinia | Greater Dandenong City of Opportunity | MonashHealth | Victoria State Government

# ប័ណ្ណព័ត៌មាន៖ គំនិតមិនត្រឹមត្រូវទូទៅអំពី អំពើហិង្សាលើស្ត្រី

គំនិតមិនត្រឹមត្រូវទី 4

## ស្ត្រីទំនងជាត្រូវបានរំលោភដោយជនចម្លែកនៅទីកន្លែងសាធារណៈ។

**ការពិត៖ ទាំងបុរសនិងទាំងស្ត្រី ទំនងជាត្រូវបានរំលោភបំពានផ្លូវភេទដោយជនណាម្នាក់ដែលពួកគេស្គាល់ ជាជាងដោយជនចម្លែកណាម្នាក់។**

យោងទៅតាមការិយាល័យស្ថិតិអូស្ត្រាលី 15 ភាគរយនៃស្ត្រីទាំងអស់ និង 3 ភាគរយនៃបុរសទាំងអស់ដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ
ត្រូវបានរំលោភបំពានផ្លូវភេទដោយបុគ្គលដែលគេស្គាល់។ នេះគឺជាការប្រៀបធៀបទៅនឹង 3.8 ភាគនៃស្ត្រីទាំងអស់ និង 1.6 ភាគរយនៃបុរសទាំងអស់ ដែលត្រូវបានរំលោភបំពានផ្លូវភេទដោយជនចម្លែកណាម្នាក់។

គំនិតមិនត្រឹមត្រូវអំពីគ្រោះថ្នាក់ដោយជនចម្លែក គឺជាមូលហេតុមួយដែលថា ស្ត្រីទំនងជាមិនសូវរាយការណ៍ពីការរំលោភបំពានផ្លូវភេទប្រព្រឹត្តដោយជនណាម្នាក់ដែលពួកគេស្គាល់ឡើយ។ ស្ត្រីទាំងនោះប្រហែលជាភ័យខ្លាចថា គ្មាននរណាម្នាក់នឹងជឿពួកគេ ឬថាពួកគេបានលើកទឹកចិត្តជនដែលប្រព្រឹត្តបទល្មើសតាមវិធីណាមួយ។ នៅពេលដែលគំនិតមិនត្រឹមត្រូវនេះត្រូវបានលាតត្រដាង ស្ត្រីអាចមានឆន្ទៈក្នុងការចេញមុខរាយការណ៍ ពីជនដែលប្រព្រឹត្តបទល្មើសដែលខ្លួនស្គាល់។

គំនិតមិនត្រឹមត្រូវទី 5

## ស្ត្រីជាច្រើនធ្វើការអះអាងមិនពិតអំពីអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានផ្លូវភេទ។

**ការពិត៖ ការអះអាងមិនពិតអំពីអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានផ្លូវភេទ គឺជាករណីកម្រណាស់។**

80 ភាគរយនៃស្ត្រីដែលធ្លាប់ឆ្លងកាត់អំពើហិង្សាពីដៃគូសម្ព័ន្ធភាពបច្ចុប្បន្ន មិនបានទាក់ទងប៉ូលិសអំពីអំពើហិង្សានេះឡើយ។

ការពិតគឺដូចគ្នាចំពោះករណីរំលោភបំពានផ្លូវភេទ។ 80 ភាគរយនៃស្ត្រី មិនបានរាយការណ៍ពីករណីរំលោភបំពានផ្លូវភេទទៅប៉ូលិសឡើយ។

វាអាចមានការលំបាកណាស់សម្រាប់ស្ត្រី ដើម្បីប្រាប់នរណាម្នាក់អំពីអំពើហិង្សា ដូច្នេះវាជាការសំខាន់ដែលយើងត្រូវជឿពួកគេ។

**ប្រភព៖**
Our Watch. (2015). Myths about violence. ទាញយកពី www.ourwatch.org.au/Understanding-Violence/Myths-about-violence

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ អំពើហិង្សាលើកុមារ



ញឹកញាប់ កុមារមានវត្តមាននៅពេលកើតមានអំពើហិង្សាក្នុងគ្រួសារនៅក្នុងផ្ទះ។




ជាង 50% ភាគរយនៃស្ត្រីអ្នស្រ្តាលីដែលជួបប្រទះអំពើហិង្សាក្នុងគ្រួសារ ក្នុងអំឡុងជីវិតរស់នៅរបស់ពួកគេ គឺកំពុងថែទាំកូនរបស់ពួកគេក្នុងអំឡុងពេលនេះ។



ម្នាក់ក្នុងចំណោមមនុស្សវ័យក្មេងបួននាក់ (អាយុចាប់ពី 12 ដល់ 20 ឆ្នាំ) បានឃើញផ្ទាល់នូវអំពើហិង្សាលើម្ដាយ ឬម្ដាយចុងរបស់ពួកគេ។

## ពេលណាស្ត្រីជាម្ដាយបានឆ្លងកាត់អំពើហិង្សា

កូនរបស់ពួកគេទំនងជាទទួលរងពីការរំលោភបំពានផងដែរ។ ការនេះ គឺដោយសារតែជនដដែលនេះឯងប្រើអំពើហិង្សាលើម្ដាយ និងកូន ឬកុមារអាចរងរបួសនៅពេលជាប់នៅក្នុងសកម្មភាពប្រើអំពើហិង្សា។ កុមារក៏អាចត្រូវបានឪពុកម្ដាយធ្វេសប្រហែសមិនយកចិត្តទុកដាក់នឹងពួកគេដែរ។

នៅពេលដែលកុមារជួបប្រទះអំពើហិង្សា និងការរំលោភបំពាន ហេតុការណ៍នេះត្រូវបានគេស្គាល់ថា **ការរំលោភបំពានលើកុមារ។**


**ប្រភព៖**

Australian Bureau of Statistics. (2006). *Personal Safety Survey*. Canberra: Australian Bureau of Statistics.

Laing, L. (2003). *Domestic violence in the context of child abuse and neglect.* Issues paper, Australian Domestic and Family Violence Clearinghouse, UNSW, Sydney.



ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្ដល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រីនិងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

City of Casey · Cardinia · Greater Dandenong City of Opportunity · MonashHealth · Victoria State Government

# ប័ណ្ណព័ត៌មាន៖ អំពើហិង្សាលើបុរស



អំពើហិង្សាលើបុរស ទំនងជាត្រូវបានប្រព្រឹត្តដោយបុរសដទៃទៀត ជាទូទៅ គឺជនចម្លែកប្រុស ឬមិត្តភ័ក្តិប្រុស ឬអ្នកស្គាល់គ្នា។

មានតែ 5 ភាគរយនៃអំពើហិង្សាលើបុរសប៉ុណ្ណោះ ត្រូវបានប្រព្រឹត្តដោយស្ត្រី ជាអតីតដៃគូសម្ព័ន្ធភាព ឬដៃគូសម្ព័ន្ធភាពបច្ចុប្បន្ន និង 3.5 ភាគរយ ដោយនារីសង្សារ (ឬអ្នកណាត់ជួប) ។




ពេលណាបុរសជាជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារ ជាទូទៅ អំពើហិង្សានេះត្រូវបាន ប្រព្រឹត្តដោយ

## សាច់ញាតិជាបុរស

ដូចជាឪពុក បងប្អូនប្រុស ឬសាច់ញាតិជន្លងឯទៀត។

**ប្រភព៖**
Australian Bureau of Statistics. (2012). *Personal Safety Survey*. Canberra: Australian Bureau of Statistics.

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ទៅលើសហគមន៍របស់យើង

អំពើហិង្សាក្នុងគ្រួសារមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុខភាព និងសុខុមាលភាពរបស់មនុស្ស។

នៅក្នុងរដ្ឋវិចតូរីយ៉ា អំពើហិង្សារបស់ដៃគូរួមសង្វាសទៅលើស្ត្រី គឺជាកត្តារួមចំណែកធំបំផុតក្នុងការបណ្ដាលឲ្យមានសុខភាពទ្រុឌទ្រោមដែលអាចបង្ការបាន និងស្លាប់មុនអាយុក្នុងចំណោមស្ត្រីដែលមានអាយុពី 15 ទៅ 44 ឆ្នាំ គឺច្រើនជាងកត្តាគ្រោះថ្នាក់ណាមួយផ្សេងទៀត ដោយមានរួមទាំងជំងឺលើសឈាម ការធាត់ និងការជក់បារី។

ស្ត្រីដែលបានឆ្លងកាត់អំពើហិង្សា ទំនងជាមានអារម្មណ៍រសាប់រសល់ និងជំងឺធ្លាក់ទឹកចិត្ត និង/ឬជំងឺពាក់ព័ន្ធនឹងការបរិភោគអាហារ។ ពួកគេទំនងជាមានបញ្ហាសុរា ជក់បារី និងប្រើប្រាស់ថ្នាំពេទ្យដែលគ្មានវេជ្ជបញ្ជា។

កុមារដែលជួបប្រទះ ឬមើលឃើញអំពើហិង្សាក្នុងគ្រួសារ អាចមានជំងឺធ្លាក់ទឹកចិត្ត រសាប់រសល់ ភាពប៉ះទង្គិចយ៉ាងខ្លាំង ភាពគឃ្លើន ឥរិយាបទប្រឆាំងនឹងសង្គម ការឲ្យតម្លៃខ្លួនឯងទាប ការភ័យខ្លាច បញ្ហាសតិអារម្មណ៍ និងទំនាស់ជាមួយនឹងក្រុមអាយុស្របាលគ្នា។

អំពើហិង្សាលើកុមារអាចបណ្ដាលឲ្យមានរបួស និងពិការភាព។

ការខាតបង់ប្រាក់សរុបដោយសារអំពើហិង្សាក្នុងគ្រួសារលើសេដ្ឋកិច្ចអូស្ត្រាលី ត្រូវបានប៉ាន់ប្រមាណថាមានចំនួន

## 13.6 ពាន់លានដុល្លារ


**ប្រភព៖**

Braaf, R. (2012). *Health impacts on domestic and family violence.* Sydney, Australian Domestic and Family Violence Clearinghouse, UNSW.

ក្រុមប្រឹក្សាជាតិដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន។ (2009) ។ *ការខាតបង់ផ្នែកសេដ្ឋកិច្ចនៃអំពើហិង្សាលើស្ត្រី និងកូន។* រដ្ឋាភិបាលសហព័ន្ធអូស្ត្រាលី ក្រសួងសេវាកម្មគ្រួសារ លំនៅដ្ឋាន សហគមន៍ និងកិច្ចការជនជាតិដើម ទីក្រុង Canberra

Richards, K. (2011). Children's exposure to domestic violence in Australia. T*rends and issues in crime and criminal justice, No. 419, June 2011.*

Vichealth ។ (មិនដឹងប្រភព)។ *របៀបដែលអំពើហិង្សាលើស្ត្រី ប៉ះពាល់ដល់សុខភាព។* ទាញយកពី www.vichealth.vic.gov.au/Programs-and-Projects/Freedom-from-violence/PVAW-overview.aspx



ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ ការគាំទ្រជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

ប្រជាជនបែរទៅរកមេដឹកជំនឿសាសនា និងសហគមន៍របស់ពួកគេ ដើម្បីសុំការណែនាំ និងជំនួយ ជាញឹកញាប់នៅក្នុងគ្រាលំបាក។ អ្នកដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារ អាចនឹងស្វែងរកជំនួយ និងដំបូន្មានពីសហគមន៍ជំនឿសាសនារបស់ពួកគេ។ វាអាចមានការលំបាកក្នុងការយល់ដឹងពីអ្វីដែលត្រូវនិយាយ ឬធ្វើ ក៏ប៉ុន្តែវាជាការសំខាន់ក្នុងការចងចាំគិតគូរអំពីអារម្មណ៍របស់គេ ហើយផ្តល់ជំនួយនិងការគាំទ្រ។ សូមចងចាំក្នុងការ៖

ជឿបុគ្គលនោះ ហើយឲ្យបុគ្គលនោះដឹងថាលោកអ្នកជឿគេ។

ស្តាប់បទពិសោធន៍របស់គេ។

មិនត្រូវមានគំនិតអវិជ្ជមានឡើយ។

ប្រាប់គេថា គេមិនទទួលការស្តីបន្ទោសដោយសារអំពើហិង្សាឡើយ។

រក្សាសម្ងាត់នូវព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គល ដ្បិតអីការប្រាប់អ្នកឯទៀតអាចដាក់គេឲ្យប្រឈមមុខនឹងគ្រោះថ្នាក់នៃអំពើហិង្សាថែមទៀត។

គោរពការសម្រេចចិត្តរបស់បុគ្គលនោះ។

ផ្តល់ព័ត៌មានត្រឹមត្រូវអំពីសេវាកម្មជំនួយទាំងឡាយដូចជា 1800 RESPECT (1800 737 732) ឬ SAFE STEPS FAMILY VIOLENCE (1800 015 188)។

ការផ្តល់ជំនួយដល់បុគ្គលម្នាក់ដែលបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារ អាចជាការពិបាកណាស់។ វាជាការសំខាន់ដែលត្រូវមើលថែទាំខ្លួនឯង ហើយចងចាំថា៖

ជំនួយ និងការគាំទ្ររបស់លោកអ្នកគឺមានសារសំខាន់។

កុំដាក់សម្ពាធលើខ្លួនឯង ដើម្បីផ្តល់ជំនួយច្រើនជាងអ្វីៗដែលលោកអ្នកអាចផ្តល់ឲ្យ។

និយាយទៅកាន់សេវាកម្មណាមួយ ប្រសិនបើលោកអ្នកមិនប្រាកដ ឬមានអារម្មណ៍រំជើបរំជួលខ្លាំង។

ប្រែសម្រួលពី៖ Domestic Violence Resource Centre Victoria (http://www.dvrcv.org.au/help-advice/guide-for-families-friends-and-neighbours)

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ តើច្បាប់ចែងពីអ្វីខ្លះអំពី អំពើហិង្សាក្នុងគ្រួសារ?

មនុស្សគ្រប់រូបមានសិទ្ធិដើម្បីរស់នៅក្នុងជីវិតដែលមានសុវត្ថិភាព ដោយគ្មានអំពើហិង្សា និងការរំលោភបំពាន។ វាជាការប្រឆាំងនឹងច្បាប់ដែលជនណាម្នាក់ដែលធ្វើឲ្យឈឺចាប់លើរាងកាយ គំរាមកំហែង ឬបង្ខិតបង្ខំ ឬបង្ខំជនម្នាក់ទៀតឲ្យមានទំនាក់ទំនងផ្លូវភេទ។

ប្រសិនបើនរណាម្នាក់ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ភ្លាមៗ ឬប្រសិនបើត្រូវបានគេរំលោភបំពានលើរាងកាយ ឬផ្លូវភេទ ឬគំរាមកំហែង ឬដើរតាមពីក្រោយ ជននោះអាចទូរស័ព្ទទៅប៉ូលិសតាមលេខ 000។

នៅក្នុងរដ្ឋវិចតូរីយ៉ា ប្រសិនបើនរណាម្នាក់ត្រូវការការការពារពីអំពើហិង្សាតទៅទៀត ពួកគេអាចដាក់ពាក្យសុំដីកាអន្តរាគមន៍។ ប៉ូលិសក៏អាចដាក់ពាក្យសុំដីកាអន្តរាគមន៍ជំនួសជននោះបានដែរ។ ដីកាអន្តរាគមន៍ គឺជាដីការបស់តុលាការដែលអាចចែងថាជនរំលោភបំពានត្រូវតែអនុវត្តតាមលក្ខខណ្ឌផ្សេងៗ ដូចជាពួកគេមិនអាចធ្វើឲ្យប៉ះពាល់ ឬគំរាមកំហែងដល់បុគ្គលនោះ ឬមិនអាចទៅជិត ឬទាក់ទងបុគ្គលនោះបានឡើយ។ បើសិនបើជនរំលោភបំពានមិនអនុវត្តតាមដីកាអន្តរាគមន៍ទេ ជននោះអាចត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។

## ការរាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារ

នៅក្នុងរដ្ឋវិចតូរីយ៉ា បុគ្គលដែលមានមុខតំណែងជាក់លាក់ ត្រូវតែរាយការណ៍ ប្រសិនបើកុមារណាមួយបានទទួលរង ឬមានការប្រឈមនឹងគ្រោះថ្នាក់លើរាងកាយ ឬការរំលោភបំពានផ្លូវភេទ។ បុគ្គលទាំងនេះរួមមានគ្រូពេទ្យ គិលានុបដ្ឋាក ឆ្មប គ្រូបង្រៀន នាយកសាលា គ្រូពេទ្យចិត្តសាស្រ្តដែលចុះឈ្មោះស្របច្បាប់ ឬជនណាម្នាក់ដែលមានសញ្ញាបត្រថ្នាក់ឧត្តមសិក្សាផ្នែកការងារយុវជន សង្គមកិច្ច ឬសុខុមាលភាពដែលធ្វើការក្នុងសេវាកម្មសុខភាព អប់រំ សហគមន៍ ឬសុខុមាលភាព។

ប្រសិនបើមេដឹកនាំសាសនាណាមួយកាន់តំណែងមួយ (ឬច្រើន) ក្នុងចំណោមតំណែងទាំងនេះ នោះពួកគេត្រូវបានតម្រូវឲ្យរាយការណ៍ពីការប្រឈមមុខនឹងគ្រោះថ្នាក់លើរាងកាយ ឬផ្លូវភេទចំពោះកុមារ។

នៅក្នុងរដ្ឋវិចតូរីយ៉ា អ្នកដឹកនាំសាសនាមិនបានតម្រូវដោយច្បាប់ឲ្យរាយការណ៍ពីអំពើហិង្សាក្នុងគ្រួសារលើមនុស្សពេញវ័យឡើយ។




**ប្រភព៖**

មជ្ឈមណ្ឌលផ្តល់ព័ត៌មានអំពីអំពើហិង្សាតាមផ្ទះ រដ្ឋវិចតូរីយ៉ា (http://www.dvrcv.org.au/help-advice/are-you-happy)
Australian Institute of Family Studies.
(https://www3.aifs.gov.au/cfca/publications/mandatory-reporting-child-abuse-and-neglect)

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្រ្តីនិងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# ប័ណ្ណព័ត៌មាន៖ តើយើងបញ្ឈប់កុំឲ្យកើតមានអំពើហិង្សាលើស្ត្រីដោយវិធីណា?

យើងអាចចាត់វិធានការដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី មុនវាកើតឡើងលើកដំបូង។ ការនេះត្រូវបានហៅថា វិធីបង្ការចម្បង។

ដំបូង យើងត្រូវតែស្វែងយល់ថាហេតុអ្វីបានជាអំពើហិង្សាលើស្ត្រីកើតមានឡើង។

## អំណាចមិនស្មើគ្នារវាងបុរស និងស្ត្រី

អំណាច និងឥទ្ធិពលដែលបុរស និងស្ត្រីមាន គឺមិនស្មើគ្នាទេ។ ជាញឹកញាប់ បុរសមានអំណាចច្រើនជាងនៅក្នុងជីវិតសាធារណៈ និងឯកជន។ ឧទាហរណ៍ ជាញឹកញាប់បំផុត បុរសមានមុខតំណែងជាអ្នកដឹកនាំនៅក្នុងនយោបាយ អាជីវកម្ម និងសាសនា។ បុរសក៏អាចមានអំណាចច្រើនជាងផងដែរ នៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ពួកគេ និងនៅក្នុងផ្ទះ។

## តួនាទី និងផ្នត់គំនិតបំផ្លើសដ៏តឹងរ៉ឹងអំពីហ្ជែនឌ័រ

តួនាទីនិងផ្នត់គំនិតបំផ្លើសអំពីហ្ជែនឌ័រ គឺជាជំនឿអំពីអ្វីទៅដែលជាអត្ថន័យនៃភាពជា 'បុរស' និង 'ស្ត្រី' ។ នេះរួមបញ្ចូលទាំងអ្វីដែលជាឥរិយាបទសមរម្យសម្រាប់បុរស និងស្ត្រី អំពីដូចជាទាក់ទងនឹងការងារ តួនាទីក្នុងគ្រួសារ ភាពជាឪពុកម្ដាយ ការកម្សាន្ត និងការស្លៀកពាក់។

ដូច្នេះ តើអ្វីខ្លះដែលជាកត្តាសំខាន់បង្កឲ្យមានអំពើហិង្សាលើស្ត្រី?

- អំណាចមិនស្មើគ្នារវាងបុរស និងស្ត្រី។
- តួនាទី និងផ្នត់គំនិតបំផ្លើសដ៏តឹងរ៉ឹងអំពីហ្ជែនឌ័រ។
- ឥរិយាបទសង្គមដែលលើកលែងទោសចំពោះអំពើហិង្សាដោយបុរស។

## ឥរិយាបទសង្គមដែលលើកលែងទោសចំពោះអំពើហិង្សាដោយបុរស

បទដ្ឋានសង្គមទាំងនេះ គឺជាជំនឿក្នុងសង្គមរបស់យើងដែលយល់ឃើញថា វាអាចទទួលយកបានចំពោះបុរសក្នុងការប្រើអំពើហិង្សា។ ប្រភេទនៃបទដ្ឋានសង្គមទាំងនេះ អាចឃើញមាននៅទូទាំងសង្គមរបស់យើងដូចជានៅក្នុងកីឡា នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ និងនៅក្នុងវិធីដែលបុរសត្រូវបានរៀបរាប់ថាជាមនុស្ស "រឹងមាំ" និង "ខ្លាំងពូកែ"។

កត្តាសំខាន់ទាំងនេះជួយគាំទ្រដល់ជំនឿ និងសកម្មភាពដែលនាំឲ្យមានការប្រព្រឹត្តចំពោះស្ត្រីដោយមិនសូវមានការគោរព និងសេចក្ដីថ្លៃថ្នូរនៅក្នុងទំនាក់ទំនងសម្ព័ន្ធភាពរបស់ពួកគេ។

កត្តាដទៃទៀតដូចជាភាពក្រីក្រ ស្រា ការឃើញអំពើហិង្សានៅវ័យកុមារ ឬការមានមិត្តភក្តិដែលប្រើអំពើហិង្សា គឺជាកត្តាជំរុញឲ្យមានអំពើហិង្សាលើស្ត្រី។ កត្តាទាំងនេះអាចរួមចំណែកឲ្យមានអំពើហិង្សាលើស្ត្រី ក៏ប៉ុន្តែមិនបណ្ដាលឲ្យកើតមានអំពើហិង្សាឡើយ។

## ដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី យើងត្រូវដោះស្រាយបញ្ហាវិសមភាពហ្ជែនឌ័រ។

ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្ដល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។

# បណ្ណព័ត៌មាន៖ សារៈសំខាន់នៃសមភាពហ្វឹនឌ័រ ក្នុងការបង្ការអំពើហិង្សាលើស្ត្រី

ការស្រាវជ្រាវបានបង្ហាញថា បណ្តាប្រទេសដែលមានសមភាពហ្វឹនឌ័ររវាងបុរស និងស្ត្រី មានអំពើហិង្សាលើស្ត្រីក្នុងអត្រាទាប។

យើងអាចដោះស្រាយបញ្ហាវិសមភាពហ្វឹនឌ័រក្នុងភាពជាបុគ្គលរៀងខ្លួននៅក្នុងសហគមន៍របស់យើង និងក្នុងសង្គមរបស់យើងឲ្យរឹតតែធំទូលាយ។

| | ឧទាហរណ៍ |
|---|---|
| **ភាពជាបុគ្គលរៀងខ្លួន** | • ការនិយាយដោយចំហប្រឆាំងនឹងផ្នត់គំនិតបំផ្លើសអំពីហ្វឹនឌ័រ។<br>• ជំទាស់នឹងឥរិយាបទដែលគាំទ្រអំពើហិង្សារបស់បុរសលើស្ត្រី។<br>• ការលើកកម្ពស់ទំនាក់ទំនងសម្ព័ន្ធភាពដែលមានការគោរពគ្នាទៅវិញទៅមក។ |
| **សហគមន៍** | • ឲ្យស្ត្រីចូលរួមក្នុងមុខតំណែងដែលធ្វើការសម្រេចចិត្ត។<br>• ឲ្យស្ត្រីឲ្យចូលរួមក្នុងមុខតំណែងថ្នាក់ដឹកនាំ។ |
| **សង្គម** | • ការគាំទ្រដើម្បីផ្លាស់ប្តូររចនាសម្ព័ន្ធ និងការអនុវត្តដែលមិនមានភាពស្មើគ្នាចំពោះស្ត្រី។ |


**ប្រភព៖**
United Nations Development Fund for Women. (unknown).
*Investing in gender equality: Ending violence against women and girls.* ទាញយកពី
www.endvawnow.org/uploads/browser/files/genderequality_vaw_leaflet_en_web.pdf



ឯកសារនេះត្រូវបានបង្កើតឡើងជាផ្នែកនៃគម្រោង CHALLENGE Family Violence ភាពជាដៃគូរវាង City of Casey, Cardinia Shire Council, City of Greater Dandenong និង Monash Health។ គម្រោងនេះបានទទួលការឧបត្ថម្ភថវិកានៅក្រោមកម្មវិធីផ្តល់ប្រាក់សម្រាប់កាត់បន្ថយអំពើហិង្សាលើស្ត្រី និងកូន ជាផ្នែកមួយនៃកម្មវិធីបង្ការបទឧក្រិដ្ឋក្នុងសហគមន៍របស់រដ្ឋាភិបាលវិចតូរីយ៉ា - ដំណោះស្រាយក្នុងមូលដ្ឋាន សម្រាប់បញ្ហាបង្ការឧក្រិដ្ឋកម្មក្នុងមូលដ្ឋាន។